ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៣ សរណន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំខួបលើកទី៥៦ "ទិវាកុមារអន្តរជាតិ ១ មិថុនា" និងខួបលើកទី៤ "ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា" ឆ្នាំ២០០៥

ក្នុងអំឡុងឆ្នាំ ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី២ ពួកហ្វាស៊ីស្តអ៊ីត្លែបានបង្កវិនាសកម្មកាប់សម្លាប់ស្ត្រី និងកុមារនៅភូមិលីឌីសែ ប្រទេសឆេក និង ភូមិអូរ៉ាឌូ ប្រទេសបារាំង។ វិនាសកម្មនេះជាបទពិសោធន៍ឈឺចាប់របស់ប្រជាជនលើពិភពលោក ដែលជាហេតុធ្វើឱ្យប្រទេសជាច្រើនលើពិភពលោកកំណត់យកថ្ងៃ ១ មិថុនា នេះ ជាទិវាកុមារអន្តរជាតិ ។ ទន្ទឹមនេះ លើសកលលោកជាពិសេស នៅក្នុងប្រទេសក្រីក្រ ឬប្រទេសអភិវឌ្ឍន៍មួយចំនួននៅតែបន្តប្រើប្រាស់ទម្រង់ពលកម្មធ្ងន់ធ្ងរមកលើកុមារ។ មានកុមារចាប់ពីអាយុ ៥ឆ្នាំ ដល់១៧ឆ្នាំ ប្រមាណ ២៤៦ លាននាក់ កំពុងធ្វើការងារ ក្នុងនោះប្រមាណជាង ១០០លាននាក់ ស្ថិតក្នុងទម្រង់ពលកម្មធ្ងន់ធ្ងរ និង ពុំមានឱកាសបានចូលរៀនសោះឡើយ។ ហេតុនេះហើយអង្គការពលកម្មអន្តរជាតិបានសម្រេចយក ថ្ងៃ១២ មិថុនា ជារៀងរាល់ឆ្នាំ ដើម្បីរំលឹកទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ។

ថ្ងៃទី២០ ខែ វិច្ឆិកា ១៩៨៩ មហាសន្និបាតរបស់អង្គការសហប្រជាជាតិ បានអនុម័តលើអនុសញ្ញាស្តីពី សិទ្ធិកុមារ ។ ឆ្នាំ១៩៩០ សន្និសីទកំពូលពិភពលោកដើម្បីកុមារ បានប្តេជ្ញាចិត្តស្តីពីបង្កើនសុខុមាលភាពរបស់កុមារឱ្យកាន់តែល្អប្រសើរឡើង ក្នុងគោលដៅលើកស្ទួយសិទ្ធិរបស់កុមារឱ្យរួចផុតពីការកេងប្រវ័ញ្ចគ្រប់រូបភាព ការធ្វើអាជីវកម្មកុមារ ការកេងប្រវ័ញ្ចផ្នែកពលកម្ម និងប្រឆាំងទម្រង់ពលកម្មធ្ងន់ធ្ងររបស់កុមារ។ ទន្ទឹមនឹងនេះ ក៏បានចេញសេចក្តីអំពាវនាវជាសកល ក្នុងគោលបំណងធានានូវអនាគតដ៏ល្អប្រសើរសម្រាប់កុមារទាំងអស់។ នៅខែ ឧសភា ឆ្នាំ២០០២ សម័យប្រជុំពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីកុមារបានឯកភាព ចេញសេចក្តីប្រកាសរួមមួយឈ្មោះ "ពិភពលោកមួយសមស្របសម្រាប់កុមារ" ដែលឯកសារនេះគឺជាក្របខ័ណ្ឌការងារសម្រាប់រដ្ឋាភិបាល និងដៃគូរទាំងអស់ ព្រមទាំងកុមារ ប្រើប្រាស់ដើម្បីសម្រេចគោលដៅ និង ដោះស្រាយការលំបាកដែលកំពុងកើតមានចំពោះកុមារ ។ ឯកសារនេះបានកំណត់បញ្ហាអាទិភាពចំនួនបួនគឺ : មួយ ការបង្កើនជីវភាពរស់នៅរបស់ស្ត្រី និងកុមារប្រកបដោយសុខភាពល្អ ពីរ ការបង្កើនគុណភាព

អប់រំ បី ការប្រយុទ្ធប្រឆាំងមេរោគអេដស៍/ជម្ងឺអេដស៍ និងបួន កិច្ចការពារកុមាររួចផុតពីការរំលោភការគេងប្រវ័ញ្ច និងអំពើហិង្សា។ មកដល់បច្ចុប្បន្ន បណ្តាប្រទេសនៅក្នុងតំបន់អាស៊ីបូព៌ា និង ប៉ាស៊ីហ្វិច បានកោះប្រជុំថ្នាក់រដ្ឋមន្ត្រីចំនួន៧លើក ដើម្បីពិគ្រោះយោបល់ និងពិនិត្យឡើងវិញអំពីការរីកចំរើនដែលសម្រេចបាន សម្រាប់កុមារកន្លងមក ព្រមទាំងចែករំលែកបទពិសោធន៍ល្អៗ និងអនុសាសន៍ថ្មីៗសំរាប់កំណត់គោលដៅនាពេលអនាគត ដើម្បីកុមារ។ លទ្ធផលនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី ៧ ស្តីពីកុមារ ដែលបានប្រារព្ធឡើងនៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា នាដើមឆ្នាំ ២០០៥ បានអនុម័តសេចក្តីប្រកាសសៀមរាប-អង្គរ ដែលគូសបញ្ជាក់ ពីការប្តេជ្ញាចិត្តរបស់បណ្តាប្រទេសក្នុងតំបន់ ដើម្បីបោះជំហានទៅមុខ និងធ្វើឱ្យសកម្មសំដៅលើកស្ទួយឱ្យ បានប្រសើរឡើងនូវការរស់រានមានជីវិត ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារនិងកុមារវ័យជំទង់។

ព្រះរាជាណាចក្រកម្ពុជាធ្លាប់បានជួបប្រទះ និងទទួលរងមហាវិនាសកម្មដ៏ធ្ងន់ធ្ងរ បង្កឡើងដោយរបបប្រល័យពូជសាសន៍ប៉ុលពត ដែលបានធ្វើឱ្យប្រជាជន យុវជន កុមារ បាត់បង់សិទ្ធិជាមនុស្ស បង្ខំឱ្យធ្វើការជាទម្ងន់ រស់នៅយ៉ាងវេទនា ក្លាយជាទាសករ រងនូវទារុណកម្ម និងការកាប់សម្លាប់ដោយអយុត្តិធម៌អស់រាប់លាននាក់។ ក្រោយថ្ងៃ៧ មករា ១៩៧៩ សិទ្ធិរបស់ប្រជាពលរដ្ឋ និងជាពិសេសសិទ្ធិរបស់កុមារនៅកម្ពុជាត្រូវបានយកចិត្តទុកដាក់ ដោយថែមទាំងបានចែងច្បាស់ក្នុងរដ្ឋធម្មនុញ្ញ និង កម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្របទៅតាមអនុសញ្ញាអន្តរជាតិផ្សេងៗដែលពាក់ព័ន្ធកុមារ។ ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពី សិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ហើយនៅឆ្នាំ២០០២ បានផ្តល់សច្ចាប័នលើពិធីសារពីរគឺ : មួយ ការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ពីរ ការជួញដូរកុមារការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់កុមារ។ នៅដើមឆ្នាំ២០០៥ ព្រះរាជាណាចក្រកម្ពុជា បាន និង កំពុងដំណើរការផ្តល់សច្ចាប័នអនុសញ្ញាលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

ក្នុងគោលដៅដើម្បីអនុវត្តឱ្យបានរឹតតែល្អថែមទៀតនូវ សិទ្ធិកុមាររាជរដ្ឋាភិបាលណែនាំចាត់តាំងទិវាកុមារអន្តរជាតិ ១ មិថុនា និង ទិវាពិភពលោកប្រឆាំងនឹងពលកម្ម កុមារ ១២ មិថុនា ឆ្នាំ ២០០៥ ដូចខាងក្រោម :

១- គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង និង អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ ត្រូវធ្វើកិច្ចសហការគ្នាជាមួយអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និង ប្រជាពលរដ្ឋដើម្បីឧបត្ថម្ភគាំទ្រ និងផ្សព្វផ្សាយជូនដល់អង្គភាពក្រោមឱវាទ និងសង្គមជាតិទាំងមូលឱ្យបានជ្រួតជ្រាបអំពីប្រវត្តិនៃទិវាកុមារអន្តរជាតិ ១ មិថុនា និង ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ។

២- ត្រូវរៀបចំពិធីមិទ្ទិញ ឬពិធីជួបជុំសំណេះសំណាលជាមួយកុមារ និង មានកម្មវិធីចាត់តាំងកំសាន្តសប្បាយរបស់កុមារនៅក្នុងមូលដ្ឋានរបស់ខ្លួន តាមលទ្ធភាពជាក់ស្តែង។

៣- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមិទ្ទិញ និង មានកម្មវិធីកំសាន្តផ្សេងៗសម្រាប់កុមារអោយបានឱឡារិក អធិកអធម ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អាជ្ញាធរដែនដីគ្រប់ខេត្ត ក្រុង ត្រូវរៀបចំចាត់តាំងអនុវត្តឱ្យបានប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង - ស្ថាប័ន
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ